សម្លេងខ្មែរនៅបរទេស

# ប្រវត្តិសាស្ត្រសើរើឡើងវិញ

# មហាពស់នាគរាជ នៃការប្រល័យពូជសាសន៍

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១១ ធ្នូ ២០០៤

★ តុកត្តាក្បាលយួនខ្លួនខ្មែរ ៖

ដើម្បីធ្វើការសិក្សាឲ្យបានប្រត្យ័ក្ស អំពីការប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ដែលបានលេចឡើងពេញទំហឹង, ថ្ងៃទី១៧ មេសា ១៩៧៥... យើងត្រូវរៀបចំដាក់សេចក្ដីចាប់ផ្ដើម (Prémisse) ឲ្យបានត្រឹមត្រូវសិន ។ បើកាលណាសេចក្ដីចាប់ផ្ដើមត្រូវវាយ «ស្នៀត» បញ្ចូលទៅក្នុងផ្លូវខុសតាំងពីដំបូងទីទៅហើយ នោះសេចក្ដីបញ្ចប់ក៏វាត្រូវធ្លាក់ចូលផ្លូវខុសទាំងស្រុងជាមិនខានដែរ ។ ធម្មតាមនុស្សជាតិយើង មិនដែលសម្លាប់ខ្លួនដោយសុទ្ធចិត្តទេ វាតែងតែមានការបង្កាប់បញ្ជាមកពីខាងក្រៅ ។ បើទោះជាយើងពិឃាតខ្លួនឯង ដោយសេចក្ដីខកចិត្តតែខ្លួនឯងក៏ដោយ ក៏ការចាញ់បញ្ឆោតនោះក៏វាជា «អំពើ» ដែល «គាបសង្កត់» មកពីពិភពខាងក្រៅដូចនោះដែរ ។ យ៉ាងណាមិញប្រជាជាតិយើង ក៏មិនបានសម្លាប់ខ្លួនឯងដោយខ្លួនឯងដែរ កាលពីខែមេសា១៩៧៥ ។ ដៃដែលសម្លាប់ខ្មែរគឺជាដៃខ្មែរពិតមែន ក៏ប៉ុន្តែខួរក្បាលដែលសម្លាប់ខ្មែរ ពុំមែនជាខួរក្បាលខ្មែរទេ ដោយហេតុថាខួរក្បាលរបស់ជនដែលសម្លាប់ខ្លួន គឺជាខួរក្បាលដែលពុំមានសេរី ។ ដូច្នេះហើយបានជាមានពាក្យថា «ក្បាលយួនខ្លួនខ្មែរ»... ហើយមនុស្ស «ក្បាលយួនខ្លួនខ្មែរ» ដ៏សំខាន់បំផុត ដែលជាប្រភពនៃមហាអន្តរាយរបស់ប្រជាជាតិខ្មែរទាំងមូល គឺមានឈ្មោះថា នរោត្តម-សីហនុ ។

គឺជាការជាក់ច្បាស់ពន់ពេក ដែលស្ដេចសីហនុជាតុកត្តារបស់យួន, រឿងនេះយើងពុំចាំបាច់ស្វែងរកភស្ដុតាងទេ ។ គេឃើញស្ដេចសីហនុនៅក្នុងឆ្នាំ១៩៧០ រត់ទៅធ្វើស្ដេចយៀកកុង ហើយបានពន្យុះទ័ពយួនខាងជើង ឲ្យមកបំផ្លិចបំផ្លាញស្រុកខ្មែរ (តើកំហុសមកពីអ្វី ? មកពីលន់នល់សិរិមត: ? រឿងនេះមិនចេះថាជាអីចឹងទេ... ពីព្រោះលោកស៊ឹម-វ៉ារបានប្រាប់ខ្ញុំថា ស្ដេចសីហនុចង់ធ្វើមេឥស្សរ: មេយៀកមិញ តាំងពីគាត់ធ្វើព្រះកូណាកាលពីឆ្នាំ១៩៥៣ម្ល៉េះ...កាលណោះសម្ដេចព្រះមាតា<កុសុម:> បានអង្វរលោកស៊ឹម-វ៉ារ ឲ្យឃាត់ព្រះកូណាកុំឲ្យរត់ចូលព្រៃ ទៅធ្វើខ្មែរឥស្សរ: ។ លោកស៊ឹម-វ៉ារបានឆ្លើយតបថា ៖ ទូលបង្គំមានសិទ្ធិអ្វីទៅឃាត់ព្រះកូណា, ព្រះកូណាជាម្ចាស់ផែនដី... ទេ ! ឯកឧត្តមអាចឃាត់បាន (សំដីរបស់ក្សត្រីកុសុម:) ឯកឧត្តមអាចធ្វើជាឪព្រះកូណាបាន !...។ ទោះជាយ៉ាងណាក្ដី តុកត្តាជាវត្ថុឥតវិញ្ញាណ, ចំណែកស្ដេចខ្មែរដែលទៅលើកទ័ពយួនឲ្យមកសម្លាប់ស្រុកខ្លួនឯង មានលក្ខណ:ជាខ្មែរត្រឹមតែជានាមប៉ុណ្ណោះ... ក៏ប៉ុន្តែ«បញ្ញាញាណ» ឬ«ព្រះតម្រិះ» ឬ«នយោបាយប្រល័យពូជសាសន៍ខ្មែរ»នេះ វាជាការវាយ«បញ្ចូលស្នៀត»របស់ជនឧក្រិដ្ឋដែលបានទទួលភោគផលទៅវិញទេ ឈ្មោះ «ផាំ-យ៉ាំងដុង» ។

ដូច្នេះបើយើងធ្វើដំណោះស្រាយ (តាមបែបបទរបស់ទស្សនវិទូក្រិក) និក្ខេបបទខុស (Thèse) ពីដើមទី... យើងនឹងបានទទួលសំយោគ (Synthèse) ខុសជាប្រាកដនៅខាងចុងចប់ ។ ប្រសិនបើយើងនិយាយថា «ខ្មែរតែងតែសម្លាប់ខ្មែរ (សេចក្ដីចាប់ផ្ដើមខុស) ស្ដេចសីហនុគាត់បានសម្លាប់ខ្មែរប្រាកដណាស់... ដូច្នេះស្ដេចសីហនុគឺជាខ្មែរ» (សេចក្ដីបញ្ចប់ខុស) នេះគឺជាដំណោះស្រាយរបៀបលីលា... (Sophisme) ។ ដើម្បីរកការពិតឃើញ យើងត្រូវនិយាយដូច្នេះវិញ ។ «យួនតែងតែសម្លាប់ខ្មែរ (សេចក្ដីចាប់ផ្ដើមត្រូវ) ស្ដេចសីហនុគាត់បានសម្លាប់ខ្មែរប្រាកដណាស់ ដូច្នេះស្ដេចសីហនុនេះ គឺជាយួន ! » (សេចក្ដីបញ្ចប់ត្រឹមត្រូវ) ។

និយាយតាមបែបបទចុងក្រោយនេះ ទើបយើងអាចយល់បាន ពី«វន្ទះបាញ់ទាំងកណ្ដាលខែចែត្រ» ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៧ មេសា ១៩៧៥ ។ ដូច្នេះ បើស្ដេចសីហនុជាតុកត្តា «ក្បាលយួនខ្លួនខ្មែរ» ទៅហើយ, ប៉ុល-ពតក៏ជាមនុស្ស«ក្បាលយួនខ្លួនខ្មែរ»... ហើយថ្ងៃក្រោយមក ហ៊ុន-សែនក៏ជាមនុស្ស «ក្បាលយួនខ្លួនខ្មែរ» ដូចគ្នាទាំងអស់ ។ ពីព្រោះអ្នកទាំងបីនេះ មានមុខមាត់ត្រឹមតែជាខ្មែរ ប៉ុន្តែ«នយោបាយ»របស់ពួកគេ គឺជា«នយោបាយយួន»... គឺជានយោបាយ«យួនប្រល័យពូជសាសន៍» ដើម្បីវាតយកទឹកដីកម្ពុជា ។ ដូច្នេះយើងត្រូវនិយាយតាមក្បួនចិនវិញ «អ្វីៗដែលយើងមើលឃើញ គឺគ្រាន់តែជាសញ្ញាឃើញ តែមិនមែនជាសញ្ញាពិត... អ្វីៗដែលយើងមើលមិនឃើញ នោះទើបបានជាសញ្ញាពិត» ។

❑

★ សត្វពស់នៅក្នុងពង (Le serpent était dans l'oeuf) ៖

នៅក្នុងរជ្ជកាលរបស់ម្ចាស់ក្សត្រីអង្គម៉ី (១៨៣៤-ព្រះអង្គម៉ីត្រូវជាក្មួយស្រីរបស់ព្រះអង្គឌួង ដូច្នេះត្រូវជាបងប្អូនជីដូនមួយរបស់ស្ដេចនរោត្តមនិងស៊ីសុវត្ថិ) ស្ដេចអណ្ណាមម៉ឹងម៉ាង បានយល់ថាប្រទេសកម្ពុជាត្រូវរលាយរលត់ផុតសូន្យអាយុនៅពេលនោះហើយ ។ ព្រះចៅអណ្ណាមបានបញ្ជូនស្ដេចត្រាញ់យួនម្នាក់ឈ្មោះទ្រឿង-មិញយ៉ាំង (ជាមួយនិងកងទ័ព១៥,០០០នាក់) មកកាន់កាប់ប្រទេសកម្ពុជា, ឲ្យមករួមដំណេកជាសាហាយស្មន់ជាមួយព្រះអង្គម៉ីអាយុ២០ឆ្នាំ (ពាក្យខ្លះថារឿងនេះពិត, ពាក្យខ្លះទៀតថាមិនពិត... ប៉ុន្តែនៅថ្ងៃក្រោយមក លុះព្រះអង្គម៉ីបានដឹងពីពាក្យចោទប្រកាន់នេះ ព្រះនាងក៏បានក្លាយទៅជាឆ្កួតលីលា) ។ ព្រះអង្គម៉ីមានឈ្មោះយួនថា ព្រះនាងង៉ុកវ៉ាង... មានងារជា មីឡាំខ្វាន់ឈួរ (ស្ដេចស្រីនៃស្រុកមីឡាំ) ចំណែកទីក្រុងភ្នំពេញមានឈ្មោះ ត្រាំងណាំយ៉ាំង ។ គឺនៅក្នុងរាជ្យអង្គម៉ីនេះឯង ដែលបានអនុវត្តនយោបាយប្រល័យពូជសាសន៍ខ្មែរដោយចំហម្ដងរួចទៅហើយ ដើម្បីធ្វើប្រទេសកម្ពុជាឲ្យក្លាយទៅជា «សំបុកឥតសត្វ»... ក្នុងប្រការសំរួលឲ្យទឹកដីខ្មែរភ្ជាប់ជាមួយនឹងទឹកដីអណ្ណាម ។ យួនក៏បានបញ្ឆោតព្រះឧបរាជអង្គអែម (ជេដ្ឋារបស់ព្រះអង្គឌួង) ព្រមទាំងពួកពលបរិវារ ឲ្យមកចូលអន្ទាក់យួននៅភ្នំពេញ រួចទ្រឿងមិញយ៉ាំងក៏បញ្ជាចាប់ព្រះឧបរាជអង្គអែម ញាត់នៅក្នុងទ្រុងដែក បញ្ជូនទៅទីក្រុងវ៉េ... (១៨៤០) ។

«សភាពការណ៍កាន់តែមានកំរិតធ្ងន់ធ្ងរឡើង ។ ពេលនោះ អុងទុងគួន (ស្ដេចត្រាញ់អណ្ណាម) ពុំមានស្គាល់អ្វីដែលជាព្រំដែននៃការលោភលន់របស់ខ្លួនទៀតឡើយ ។ ទ្រឿង-មិញយ៉ាំងបានចង់ផ្លាស់ប្ដូរលទ្ធិសាសនារបស់ជនជាតិខ្មែរ ដោយដាក់សាសនាអណ្ណាមមកជំនួសវិញ បានបង្ខំព្រះសង្ឃឲ្យចាកសិក្ខាបទចេញពីវត្តអារាម, បានបញ្ជាឲ្យកាប់ដើមពោធិ, ឲ្យគាស់រំលើងព្រះពុទ្ធបដិមាករ, ឲ្យកំទេចបំផ្លិចបំផ្លាញចេតិយនានា...។ លើសពីនេះទៅទៀត ដើម្បីបំបាត់អ្វីៗដែលមានលក្ខណ:ជាខ្មែរ, អុងទុងគួនក៏បានចាប់បញ្ជូនកុង្សីសេនាបតីរបស់ព្រះអង្គម៉ីទៅព្រៃ-

នគរ មានជាពិសេសចៅហ្វាឡុង, ចៅពញាហ៊ូ, ក្រឡាហោមគីង ដោយយកលេសថា ព្រះចៅអណ្ដាមចង់ចរចាជាមួយពួកខ្លួន នៅពេលដែលព្រះឧបរាជ (អង្គអែម) ទៅដល់ ។ បន្ទាប់មក ជននេះបានទាំងចាប់បញ្ជូនមហាក្សត្រីអង្គម៉ី, ព្រះនាងពោ ប្អូនស្រីបន្ទាប់ដែលមានឋានៈជាឧបរាជ ព្រមទាំងព្រះអង្គស្ងួន ប្អូនគេបង្អស់ថែមទៀត ។ បងស្រីបំផុតឈ្មោះអង្គប៉ែន អាយុ៣២ឆ្នាំ ត្រូវយួនយកទៅជ្រមុជទឹកសម្លាប់នៅលង់ហោ (វិញឡុង) ។

ដូច្នេះ នយោបាយពិឃាតវង្គាលរបស់យួនផាំ-យ៉ាំងដុង ទៅលើជនជាតិខ្មែរតាមរយៈទីងមោង ឬ«អ្នកតាមបញ្ចូលរូប»ប៉ុល-ពត នៅសម័យមេសា៧៥... គឺគ្រាន់តែជាការបន្តភ្ជាប់នយោបាយរបស់ទ្រឿង-មិញយ៉ាំងមកពីសម័យរជ្ជកាលព្រះអង្គម៉ីតែប៉ុណ្ណោះឯង ។ ខុសគ្នាត្រង់ថា កាលសម័យទ្រឿង-មិញយ៉ាំងយួនបានបំបាត់ពូជស្ដេចខ្មែរដោយចំហ ចំណែកនៅក្នុងខែមេសា១៩៧៥ យួនចង់សំដែងល្ខោនឲ្យពិភពលោកឃើញថា ខ្មែរបានធ្វើអត្តឃាត ពោល«ខ្មែរបានសម្លាប់ខ្មែរ»ដោយដៃរបស់ខ្លួនឯងទេតើ ។ មនុស្សសម្លាប់ខ្លួនឯងនោះ តើមានព្រះឥន្ទព្រះអង្គឯណាជួយប្រោសលោះទៅបាន ?

តាមពិតនៅក្នុងខែមេសា១៩៧៥ មហាពស់នាគរាជនៃការប្រល័យពូជសាសន៍ ដែលមានប៉ុល-ពតជាក្បាលម៉ាស៊ីននោះ វាបានរីកធំធាត់ ហើយខ្ពស់ស្គឹមស្កៃជាងត្នោតលៃទៀតទៅហើយ ដូចជាម៉ៅ-សេទុងនៅកណ្ដាលមហាបដិវត្តន៍វប្បធម៌ជាមួយនិងពួកឆ្មាំក្រហមអីចឹងឯង (ដែលគាត់នេះមាន«ក្បាលជាយួនតែខ្លួនជាចិន»... សូមកុំភ្លេចថា «យួន»ជារាជការចិនកាលសម័យស្ដេចម៉ុងគ្គោល គូប៊ីឡៃក្រាន់ កាន់កាប់ក្រុងប៉េកាំង ។ សព្វថ្ងៃនេះ ប្រាក់ចិននៅមានឈ្មោះថា ១«យួន» ២«យួន» ។

ដូច្នេះ យើងគួរត្រឡប់ទៅ១៩៦៨វិញ ដែលពស់នាគរាជនៅក្នុងពងនៅឡើយ ហើយមិនទាន់មានឈ្មោះថាប៉ុល-ពតទេ តែជានរោត្តម-សីហនុ ។ ធម្មតាស្ដេចដែលសម្លាប់ស្រុកខ្លួនឯង គឺជាស្ដេចដែលធ្វើអត្តឃាតដ៏ពិតប្រាកដ ។ នៅក្នុងឆ្នាំ១៩៦៤, ស្ដេចសីហនុបានចាប់ផ្ដើមពិឃាតប្រទេសកម្ពុជារួចហើយ ដោយអនុញ្ញាតឲ្យកងទ័ពយៀកកុង មកតាំងនៅក្នុងដីខ្មែរ តាមជួរព្រំដែនខាងកើត ។ នៅក្នុងពេលជាមួយគ្នានោះ ស្ដេចសីហនុបានទាត់ជំនួយអាមេរិកាំង ព្រមទាំងប្រារព្ធកម្មវិធីសេដ្ឋកិច្ចកុម្មុយនិស្ដ ដោយធ្វើជាតូបនិយកម្ម ។ ទាំងនេះហើយជាអំពើសម្លាប់ខ្លួន ពីព្រោះថា ដោយមានជំនួយអាមេរិកាំងក៏ដោយ ក៏ថវិកាប្រចាំឆ្នាំនៃរដ្ឋាភិបាលកម្ពុជា ទប់ទល់នឹងចំណាយមិនបានផង ចុះទម្រាំឥតជំនួយអាមេរិកាំងទៅទៀត តើជាតិខ្មែរបានអ្វីការពារខ្លួន ? អំពើឆ្កួតលីលាកាន់តែឡើងកំរិតធ្ងន់ធ្ងរទៅទៀត នៅក្នុងឆ្នាំ១៩៦៥... ដោយស្ដេចសីហនុបានកាត់ផ្ដាច់ចំណងទូតពីសហរដ្ឋអាមេរិក ។ ទង្វើដូច្នេះ ធ្វើម្ដេចនឹងអនុញ្ញាតឲ្យព្រះអង្គគេចផុតពីចង្កូមឆ្កែចចកផាំ-យ៉ាំងដុង ? ប៉ុន្តែស្ដេចសីហនុមិនត្រឹមតែមិនបានប្រឹងរត់គេចប៉ុណ្ណោះទេ គឺទ្រង់បានខំបោលសំរុកចូលថែមទៀត ។ ប្រទេសកម្ពុជាមានកងទ័ព៣៥,០០០នាក់ ក្ររខេករខាក ខ្វះសម្ភារៈទំនើប (ជាពិសេសគ្រឿងអាវុធ) ដែលស្ដេចបានប្រគល់ឲ្យបុរសទុគត លន់-នល់ ជាអ្នកចាត់ចែង ឲ្យកសាងផ្លូវថ្នល់ សង់ស្ពាន ជីកស្រះ ។ កងទ័ពសំរាប់ច្បាំងនៅព្រំប្រទល់ឥតមានទេ... ហើយប្រទេសកម្ពុជាក៏បានក្លាយទៅជាប្រទេសឥតព្រំប្រទល់ ពីព្រោះនៅព្រំប្រទល់មានសុទ្ធតែយៀកកុង, ហើយស្ដេចសីហនុបានពោលដោយអំនួតថា ៖ «ប្រទេសកម្ពុជាជាកោះសន្តិភាព នៅចំកណ្ដាលឃ្លាំងរំសេវ» ពោលប្រទេសនេះរង់ចាំតែថ្ងៃផ្ទុះស្លាប់តែប៉ុណ្ណោះ ! ។ តាំងពីឆ្នាំ១៩៦៨ដល់១៩៧០ សម្ដេចសីហនុបានបញ្ជាឲ្យដឹកគ្រឿងអាវុធយុទ្ធភ័ណ្ឌរបស់ចិន យកទៅឲ្យយៀកកុង តាមជួរឡានកុងវ៉ូយោធា ឡើងភ្លូកទឹកភ្លូកដី តាំងពីក្រុងកំពង់សោមរហូតទៅដល់មេមត់ ។ គ្រឿងអាវុធទាំងនេះ ទៅថ្ងៃមុខទៅ គឺសំរាប់ពិឃាតប្រទេសកម្ពុជា មិនមែនសំរាប់ច្បាំងនឹងអាមេរិកាំងទេ ។ ដើម្បីឲ្យយៀកកុងមានប្រាក់ទិញស្បៀង ថ្នាំពេទ្យ ទិញទាំងគ្រូពេទ្យខ្មែរនិងគ្រូពេទ្យបារាំងទៅព្យាបាលពួកខ្លួននៅក្នុងរូងដីថែមទៀត សម្ដេចសីហនុហើយនិងសម្ដេចសឺន-សាន បានឲ្យគេដឹកសន្លឹកប្រាក់រៀល (ក្រដាស់៥០០) ទាំងតោន ដែលមិនទាន់ទាំងកាត់ផង យកទៅប្រគល់ឲ្យពួកនេះ ជាមួយនឹងគ្រឿងអាវុធ ។ (ដូច្នេះ... ស្ដេចអត្តឃាតបានបញ្ឆោតតាលន់-នល់ហើយនិងប្រជាជាតិខ្មែរទាំងមូល ឲ្យភពប្រសព្វជាមួយពួកយៀកកុង, ឲ្យពឹងផ្អែកជីវិតខ្លួនទៅលើពួកជនបរទេស ដែលជាសត្រូវស្នូរពូជតាំងពីដូនតា ។ ព្រោះស្ដេចសីហនុជាអាយ៉ង, ជាទីងមោង, ជា«អ្នកតាបញ្ចូលរូប» របស់ផាំ-យ៉ាំងដុង ។ ដូច្នេះបើមាន«រដ្ឋប្រហារ»នៅថ្ងៃទី១៨មិនា១៩៧០ ដែលអនុញ្ញាតឲ្យទ័ពយួន ទាំងខាងជើងទាំងខាងត្បូង ចូលមកប្លន់ទឹកដីខ្មែរទាំងកណ្ដាលថ្ងៃត្រង់ គឺផាំ-យ៉ាំងដុងជាអ្នកបង្កើតរដ្ឋប្រហារនេះ តាមរយៈស្ដេចអត្តឃាតនរោត្តម-សីហនុនោះឯង ។ ប៉ុន្តែយួនមិនបានមកយកអំណាចឲ្យស្ដេច«ចំកួតហ្លួង»វិញទេ... ប៉ុន្តែបានមកសាបព្រួសបង្កើតពួកខ្មែរក្រហម ឲ្យក្លាយទៅជាមហានាគរាជប្រល័យពូជសាសន៍ សំរាប់បង្ហើយប្រជាជាតិខ្មែរ ក្នុងប្រការយកទៅភ្ជាប់នឹងប្រជាជាតិវៀតណាម (ដូចពិភពលោកបានឃើញស្រាប់ហើយ!) ។

ដូច្នេះ «មហាពស់នាគរាជសម្លាប់ពូជខ្មែរ» បានចាប់បដិសន្ធិនៅក្នុងសម័យដឹកគ្រាប់ឲ្យយៀកកុងនៃឆ្នាំ១៩៦៨នោះឯង ។ សូម្បីតែមហាប្រទេសចិន ក៏បានត្រូវចាញ់បោកផាំ-យ៉ាំងដុង តាមរយៈ«តុកត្តាក្បាលយួនខ្លួនខ្មែរ» នរោត្តម-សីហនុដូចគ្នាដែរ ។ តទៅនេះ ជាសេចក្ដីដកស្រង់នៃអត្ថបទមួយរបស់លោក Nayan Chanda នៅក្នុងសៀវភៅរបស់លោកដែលមានឈ្មោះថា «បងប្អូនជាខ្មាំងសត្រូវ» (Brother Ennemy) ៖

«ទីក្រុងប៉េកាំងបានបញ្ជូនបន្ថែមទៀត នៅចន្លោះឆ្នាំ១៩៦៥-១៩៦៨ នូវជំនួយដឹកនាំដល់ក្របខណ្ឌនៃគណបក្ស (កុម្មុយនិស្ដ) វៀតណាម និងពួកក្រុមប្រឹក្សាយោធា ដែលឆ្លងកាត់តាមដីចិនរហូតដល់ដីលាវ ដោយផ្ដល់រថយន្តកាម្យ៉ុង៣០,០០០គ្រឿង ដើម្បីដឹកគ្រឿងអាវុធរបស់ចិនរាប់ពាន់តោន ឆ្ពោះទៅផ្លូវលំហូ-ជីមិញ ព្រមទាំងបានសំរុះសំរួលជាមួយនឹងសីហនុ ដើម្បីដឹកស្បៀងនិងអាវុធតាមនាវា យកទៅផ្ដល់ឲ្យយៀកកុងតាមរយៈប្រទេសកម្ពុជា...» (Brother Ennemy, p.129) ។

«នៅខែមេសាឆ្នាំ១៩៨០ ខ្ញុំ (Nayan Chenda) បានធ្វើដំណើរទៅទីក្រុងប៉េកាំង ដើម្បីទៅសម្ភាសន៍លោក ហាន់-ញ៉ាន់ឡុង អនុរដ្ឋមន្ត្រីចិនផ្នែកកិច្ចការបរទេស អតីតដៃស្ដាំរបស់ខ្មោចលោកជូ-អេនឡាយ ក្នុងប្រការរៀបចំតុបតែងនយោបាយចិន (ដឹកគ្រាប់ឲ្យយៀកកុង) នៅដែនដីឥណ្ឌូចិន ។ ខ្ញុំបានសួរគាត់ថា ម្ដេចបានជាប្រទេសចិន បន្ទាប់ពីបានគាំទ្រវត្តមានរបស់វៀតណាមនៅលាវនិងកម្ពុជា កាលពីសម័យសង្គ្រាម ហើយឥឡូវបែរជាប្រឆាំងនឹងវត្តមាននេះទៅវិញ ? ពេលនោះលោកហាន់មានការរសាប់រសល់ជាខ្លាំង (ច្បាស់ជាគាត់នេះជាក្បាល«យួនខ្លួនចិន» ឬជាភ្នាក់ងារយួនតែម្ដង, បើពុំនោះសោតគាត់មិនត្រូវមានការភ័យបារម្ភទេ)... លោកហាន់បានឆ្លើយមកខ្ញុំវិញថា ៖ «កាលសម័យនោះ, ពួកគេ (វៀតណាម) បានយកមាគ៌ាឆ្លងកាត់ប្រទេសលាវនិងប្រទេសកម្ពុជា ជាមាគ៌ាសំរាប់តស៊ូប្រយុទ្ធជាមួយនឹងសហរដ្ឋអាមេរិក ។ ជាធម្មតាពេលនោះយើងបានជួយគាំទ្រពួកគេ... រឿងមួយដែលយើងពុំបាននឹកស្មានសោះ គឺប្រទេសមួយដែលធ្លាប់មានបុកត្អើងជាចក្រពត្តិនិយមនៅក្នុងអតីតកាល ស្រាប់តែមានបុកពារកោងកាចម្ដងទៀតទៅលើប្រទេសជាបងប្អូន នៅពេលដែលជោគជ័យមកដល់»... ។ ទំរាំតែចិនស្ដាយក្រោយ ប្រជារាស្ត្រខ្មែរបានស្លាប់អស់៣លាននាក់ទៅហើយ...

★★★នៅក្នុងឆ្នាំ១៩៦៤, ស្តេចសីហនុគ្រាន់តែជា«ថ្មអ្នកតាបញ្ចូលរូប» ។ ក៏ប៉ុន្តែអ្នកកាន់អំណាចពិតប្រាកដ គឺសម្តេច«ព្រះរាជគ្រូ»... គឺឯ.ឧ.សឺន-សាន ។ លោកសឺន-សានបានហៅសម្តេចសីហនុថាជា «អ្នកតាអាចម៍ឆ្កែ»... «ហើយអ្នកតាអាចម៍ឆ្កែនេះ ខ្លាំងពូកែណាស់» រួចហើយឯ.ឧ.សឺន-សានក៏អង្គុយសំពះស្តេចសីហនុក្បាលបន្ទាបជិតដល់ដី ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរទាំងមូលបោលរត់ទៅរកសេចក្តីស្លាប់ ជាមួយនឹង«អ្នកតាអាចម៍ឆ្កែ» ។ នៅពេលដែលសម្តេចសីហនុកំពុងតែវក់ក្រសាលសប្បាយក្នុងភ្លេងភ្លាត់... ក្នុងរាត្រីស្រមោសរក្នុងផលិតកម្មភាពយន្ត, ក្នុងតណ្ហាស្រីញី ដូចនៅក្នុងវាំងស្តេចចាម ហារី ជិតពេលដែលប្រទេសចំប៉ាត្រូវរលត់រលាយ (កាលណាវរជនណាម្នាក់យកប្រពន្ធទៅថ្វាយ ស្តេចសីហនុតែងប្រគល់តំណែងដល់កំពូល... លោកជិន-រ៉េនបានយកប្រពន្ធទៅថ្វាយស្តេច ក៏បានទទួលដំណែងជារដ្ឋមន្ត្រីក្រសួងឃោសនាការ, ចំណែកអ្នកស្រីអ៊ុំង-ម៉ុំង ក៏បានទទួលតំណែងជារដ្ឋលេខាធិការក្រសួងទេសចរណ៍...។ រឿង«ប្រាជ្ញាបុណ្យផង ឡើងតាមថ្នក់សំពត់»ទាំងអស់នេះ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អ្នកម្នាងម៉ូនិក ដើម្បីធ្វើឲ្យស្តេចឆ្កួតវង្វេង)... នៅក្នុងពេលជាមួយគ្នា សម្តេចរាជគ្រូ«សឺន-សាន» ក្តោបក្តាប់កិច្ចការសំខាន់ៗទាំងអស់នៅក្នុងព្រះរាជាណាចក្រ ។ លោកសឺន-សានមានឋានៈជានាយករដ្ឋមន្ត្រី ពោលគឺគ្រប់គ្រងទៅលើគ្រប់ក្រសួងរាជការ, លោកកាន់កាប់កិច្ចការបរទេស ពោលគឺមានទំនាក់ទំនងជាមួយគ្រប់ប្រទេសខាងក្រៅ, លោកមានតំណែងជាទេសាភិបាលធនាគារជាតិកម្ពុជា ពោលគឺក្តោបក្តាប់សេដ្ឋកិច្ចនៃប្រទេសជាតិទាំងមូល...។ ហើយសកម្មភាព ថាមពលនៃព្រះរាជាណាចក្រខ្មែរ កាលសម័យនោះ គឺមានសំរាប់តែពិឃាតប្រទេសកម្ពុជា នៅក្នុងខែមិនា១៩៧០ក្រោយមក ។ នៅពេលដែលសម្តេច«រាជគ្រូ» ថយខ្លួនទៅសំរាកនៅប្រទេសបារាំង នៅក្នុងឆ្នាំ១៩៦៨... ប្រទេសកម្ពុជាបានរមៀលមកដល់មាត់ជ្រោះមរណៈរួចទៅហើយ ។

ជាចុងបញ្ចប់, «ព្រះរាជគ្រូ» បានសរសេរលិខិតមួយទៅជំរាបលា «អ្នកតាអាចម៍ឆ្កែ» ដោយមានសេចក្តីដូច្នេះថា ÷ «ទូលបង្គំសូមថយខ្លួនទៅចូលនិវត្តន៍ ដោយដំណើរចំអើតជើងលបៗ» (ពោលដូចចោរលួចសេះ) (**Je prends ma retraite sur la pointe de mes pieds**) ។ ព្រះរាជគ្រូមានកំនិតព្រហើនណាស់... គាត់ឃើញថាស្តេចមាន«បញ្ញាសូន្យ» ទៅហើយ ទើបបានជាហ៊ានប្រាប់ពីធម្មជាតិពិតប្រាកដរបស់គាត់ ជាភ្នាក់ងារចារកិច្ចជាន់ខ្ពស់របស់វៀតណាម ។

❑

★ <u>ឆ្នាំ១៩៦៦ – សត្វពស់លូនចេញពីស្រោម</u> ÷

នៅចុងឆ្នាំ១៩៦៦, ស្តេចសីហនុបានប្រើឯ.ឧ.ចៅ-សេង ឲ្យចោទឧត្តមសេនិយលន់-នល់ថា ជាស៊ីបហារតូខ្មែរ... ពោលគឺមានគំរោងការក្បត់ស្តេច ដោយឃុបឃិតជាមួយសេអ៊ីអាអាមេរិកាំង ។ លោកលន់-នល់បានស្នើរ (តាមរយៈវិទ្យុជាតិ) ជួបលោកចៅ-សេង ដើម្បីដោះស្រាយពីការចោទប្រកាន់ធ្ងន់ធ្ងរនេះ។ លោកចៅ-សេងមិនបានយល់ព្រម ហើយបែរជាយល់ថា លោកលន់-នល់មានបំណងពិឃាតរូបលោក ។ ស្តេចសីហនុក៏ដកលោកលន់-នល់ ព្រះរាជបំរើដ៏ស្មោះត្រង់ជាងគេបំផុតរបស់ទ្រង់ចេញពីតំណែងអគ្គមេបញ្ជាការយោធា ហើយបង្ខំលោកឲ្យទទួលតំណែងជានាយករដ្ឋមន្ត្រីវិញ ។ ឧត្តមសេនិយឥតកងទ័ពធ្វើការបំរើនយោបាយសម្តេចឪតាមជនបទបានប្រមាណជា៥ខែ... សម្តេចឪក៏បានប្រើឧត្តមសេនិយញ៉ឹក-ជូឡុង ទៅពិឃាតឧត្តមសេនិយលន់-នល់ ។ តាមពិតគឺជានយោបាយរបស់យួន ធ្វើឲ្យស្តេចសីហនុហើយនិងលោកលន់-នល់បែកបាក់គ្នា (នៅថ្ងៃទី៩ មេសា ១៩៦៧, លោកញ៉ឹក-ជូឡុង ហៅ «តា-ស ឬតាប៊ឹត» ដែលឡើងកាន់តំណែងជាអគ្គមេបញ្ជាការកងទ័ព បាននាំលោកលន់-នល់ ហៅ «លោកតាខ្មៅ» ជិះឡានហ្ស៊ីបទៅក្រឡាប់នៅលើភ្លឺស្រែមួយនៅខេត្តកំពង់ស្ពឺ, លោកញ៉ឹក-ជូឡុងពុំមានរលាត់ស្បែកអ្វីទាំងអស់ ចំណែកលោកលន់-លន់ ដោយមានរបួសជាទម្ងន់ ក៏បានផ្ញើលិខិតលាលែងពីតំណែងនាយករដ្ឋមន្ត្រីទៅសម្តេច ពោលលោកលន់-នល់ឥតមានមុខតំណែងអ្វីទាំងអស់ ដូចមនុស្សស្រាត) ។

នៅក្នុងខែឧសភាឆ្នាំ១៩៦៧, ពេលដែលលោកលន់-នល់កំពុងព្យាបាលខ្លួន, លោកញ៉ឹក-ជូឡុង នាយសេនាធិការកងទ័ព ក៏បានបញ្ជាឲ្យលោកសក្តិប្រាំ ឆាយ-ឡាយ (មេទាហានប្រចាំខេត្តបាត់ដំបង) ប្លន់ដីអ្នកស្រុកនៅសំឡូត ។ លុះដល់អ្នកស្រុកងើបឡើងបះបោរ ក៏ឲ្យបង្ក្រាបការបះបោរនេះ ដោយពិឃាតរង្គាល រួចហើយចោទប្រជាជនខ្មែរនៅសំឡូតថា ជាពួកខ្មែរក្រហម ។

ដូច្នេះ «ពស់នាគរាជ» បានចាប់ផ្តើមសាបព្រួសនូវភេរវកម្មរបស់ខ្លួនរួចហើយ ។ គ្មាននរណាដឹងថា ការភ្ញាស់ «ពស់នាគរាជ» ឲ្យចេញពីស្រោម ជាស្នាដៃរបស់លោកញ៉ឹក-ជូឡុងសោះ ព្រោះ«តាប៊ឹត»បានយកលោហិតខ្មែរនៅសំឡូត យកមកលាបប្រឡាក់ដៃរបស់ឧត្តមសេនិយលន់-នល់ ដែលស្តេចសីហនុចោទថា ជា«ស៊ីបហារតូខ្មែរ», រួចហើយ«តាប៊ឹត» ក៏ធ្វើការ«ថ្លិនភ្នែក» បញ្ឆោតមតិមហាជន ថាគាត់មាន«ដៃស្អាត»គ្មានបានប្រព្រឹត្តអ្វីទាំងអស់ ក្រៅតែពីទៅប៊ឹតនាងសាក់ស៊ីស្បោងយ៉ាងសន្ធឹកសន្ធាប់ នៅក្នុងខ្សែភាពយន្ត «ការសប្បាយក្នុងការរស់» របស់នរោត្តម-សីហនុ ។ នៅក្នុងពេលជាមួយគ្នា ស្តេចទីងមោងតុកតារបស់យួននេះ បានអួតអាងដោយខ្លួនឯងថា ទ្រង់បានបញ្ជាឲ្យសម្លាប់ខ្មែរក្រហមបីពាន់នាក់ ហើយថាទ្រង់«គ្មានបាបទេ» ដោយទ្រង់មិនទាំងបានយល់សប្តិអាក្រក់ផង... (ថ្ងៃក្រោយមក«អ្នកតាអាចម៍ឆ្កែ»នេះ ពោលពាក្យសម្លាប់ខ្លួនរហូតដូចជាថាទ្រង់មិនគោរពច្បាប់រដ្ឋធម្មនុញ្ញជាតិទេ ទ្រង់«គោរពតែច្បាប់ព្រៃ» -ឆ្នាំ១៩៦៧- នៅកណ្តាលសន្និសិទនៅក្រុងប៉ារីស ទ្រង់ថ្លែងថា ទ្រង់«គាំទ្រការប្រល័យពូជសាសន៍» នៅពេលចូលទៅដល់«ណាំយ៉ាង» របស់ហេង-សំរិន ទ្រង់ពោលថា «មិនបានឃើញជនវៀតណាមមួយគ្រាប់ផង») ។

ជាបន្ទាប់មក, មានពាក្យចចាមអារាមចេញមកពីវាំងស្តេចសីហនុថា លោកលន់-នល់ (ស៊ីបហារតូខ្មែរ) បានបង្ក្រាបប្រជាជនបះបោរនៅសំឡូត ។ លោកចៅ-សេង (ស៊ីបង់ឱ្រយ៉ូខ្មែរ) មានការភិតភ័យក៏ភៀសខ្លួនទៅប្រទេសបារាំង ។ លោកខៀវ-សំផន, ហ៊ូ-នឹម, ហ៊ូ-យន់ (បញ្ញាជនប្រួចិន) រត់ចូលព្រៃ ទៅសហការជាមួយមេខ្មែរយៀកមិញប៉ុល-ពត, អៀង-សារី ដែលទទួលបញ្ជាពីមេយៀកមិញកំពូលជួន-មុំ នៅទីក្រុងប៉ារីស (មុននឹងរត់ចូលព្រៃ ពួកអ្នកទាំងបីនាក់នេះ បានទៅសំណាក់នៅផ្ទះលោកឈាន-វ៉ម, ដែលពុំមែនជានរណាក្រៅពីដៃស្តាំរបស់«ព្រះរាជគ្រូ»សឺនសាន ក្នុងបញ្ហាសេដ្ឋកិច្ច ព្រមទាំងជាកូនប្រសាររបស់វាំងជួន និងជាបងថ្លៃរបស់ជួន-មុំ, ជួន-ជឿន, ជួន-ប្រសិទ្ធនោះឯង ដែលសុទ្ធសឹងតែជាមេខ្មែរយៀកមិញទាំងអស់) ។

❑

★ <u>ប្រជាជាតិត្រូវបណ្តាសាររបស់ព្រះ</u> ÷

ប្រជាជាតិរបស់ខ្មែរយើង ក៏ហាក់ដូចជាត្រូវបណ្តាសាររបស់ព្រះ... ហើយពួកយៀកកុងនេះ គឺជាជម្ងឺអាសន្នរោគរបស់ព្រះ (**Le fléau de Dieu**) ។ ដោយមានការបាញ់ប្រហារបញ្ញាជនខ្មែរសេរី ប្រទេសខ្មែរត្រូវដាច់ចំណងមេត្រីពីសហរដ្ឋអាមេរិក ។ ដោយមានការពិឃាតនៅស្រុក

សំឡុត កម្ពុជាក៏ត្រូវមានទំនាស់ជាមួយប្រទេសចិន ។ ក្នុងសម័យនោះ ស្តេចខ្មែរ គឺជាស្តេចអស់ផ្លូវ...

នៅដើមឆ្នាំ១៩៦៩, លោកនិចសុនបានឡើងកាន់តំណែងប្រធានាធិបតីនៃសហរដ្ឋអាមេរិក ហើយបានប្រកាសនូវការសំរេចចិត្តរបស់លោក ដកកងទ័ពអាមេរិកាំងចេញពីវៀតណាម ។ «អ្នកតាអាចម៍ឆ្កែ» ទីងមោងរបស់វៀតណាម មានការ«ភិតភ័យ» ក៏សរសេរអត្ថបទថ្កោលទោសយៀកកុងនិងយៀកណាមខាងជើង បោះផ្សាយក្នុងទស្សនាវដ្ដី «Le Sangkum» របស់ខ្លួន ហើយក៏ជំរុញឲ្យលោកលន់-នល់ជាមួយនិងប្រជាជាតិខ្មែរទាំងមូល ដេញយួនចេញពីទឹកដីខ្មែរ ។ គំរោងការនេះ អសប្បុរសខ្លាំងពេកណាស់ ពីព្រោះមិនមែនឲ្យលោកលន់-នល់សម្លាប់យួនទេ គឺឲ្យយួនសម្លាប់លោកលន់-នល់ ដោយហេតុថាកងទ័ពខ្មែរមានតែចបប៉ែល ហើយនិងបង្គីរ តើបានអ្វីទៅសម្លាប់កងទ័ពយួន២០០,០០០នាក់ប្រដាប់ដោយអាវុធតាំងពីក្បាលដល់ចុងជើងនោះ ?

នៅខែកក្កដា១៩៦៩, ស្តេចសីហនុក៏បានស្នើឲ្យលោកលន់-នល់កាន់តំណែងជាប្រមុខរដ្ឋាភិបាល ។ លោកលន់-នល់បានបដិសេធ ពីព្រោះពេលនោះប្រពន្ធរបស់គាត់, លោកជំទាវខេង កំពុងមានជម្ងឺមហារីក ហើយបានផ្ដែផ្ដាំដល់លោកឧត្ដមសេនិយថា «កុំឲ្យចង់ធ្វើធំ» ។ ស្តេចសីហនុមិនអស់ចិត្ត ក៏បានបញ្ជូនម៉ែក្មេក, អ្នកស្រីប៉ោមពាង ម្ដាយអ្នកម្នាងម៉ូនិក ទៅលួងលោមលោកលន់-នល់អស់ចំនួន៣ថ្ងៃ ទើបលោកឧត្ដមសេនិយទទួលយល់ព្រមបំពេញបេសកកម្មនេះ ។ ដូច្នេះ «រដ្ឋាភិបាលស្រោចស្រង់ជាតិ» សំរាប់«ដេញយួន»របស់លននល់-សិរិមតៈ គឺជាស្នាដៃប្រចះត្រចង់របស់យួនទេតើ ។ យួនតែងតែដាក់អ្នកដឹកនាំពីរនាក់ដូច្នេះរហូតដើម្បីឲ្យអ្នកទាំងពីរនេះកាប់សម្លាប់គ្នាឯង ៖ លន់នល់-សិរិមតៈ, ប៉ុលពត-អៀងសារី, ហ៊ុនសែន-ជាស៊ីម...

នៅខែសីហា១៩៦៩ «រដ្ឋាភិបាលស្រោចស្រង់ជាតិ»ក៏ត្រូវបង្កើតឡើង ។ នៅពេលជាមួយគ្នានោះ សម្ដេចសីហនុក៏សុខចិត្តដាក់ឲ្យមានស្ថានទូតអាមេរិកាំងឡើងវិញ នៅទីក្រុងភ្នំពេញ គឺដើម្បីបង្ហាញឲ្យឃើញថា លន់-នល់កំពុងតែមានការឃុបឃិតជាមួយនឹងអាមេរិកាំងដើម្បីទំលាក់ ។

នៅក្នុងខែមិនា១៩៧០... ស្តេចសីហនុក៏បានបញ្ជាឲ្យលោកលន់-នល់រៀបចំធ្វើបាតុកម្មប្រឆាំងនឹងវត្តមានរបស់យួននៅក្នុងដីខ្មែរ ។ នៅពេលដែលលោកកំពុងតែទទួលជោគជ័យក្នុងប្រការនេះ ក៏ស្រាប់តែស្តេចសីហនុចោទប្រកាន់លោកពីប្រទេសបារាំងមកថា លោកជា«ជនក្បត់» ដោយទទួល«យកលុយដុល្លារអាមេរិកាំង» ។ គឺជាការយកសាំងចាក់លើភ្លើង... ក្នុងរំពេជនោះស្រុកខ្មែរក៏កើតអានាធិបតេយ្យ ដោយលោកឧត្ដមសេនិយត្រួតលើសភាពការណ៍មិនបាន ពីព្រោះលោកបានក្លាយទៅជា«ជនក្បត់» ។ ផាំ-យ៉ាំងដុង ឆ្លៀតឱកាស ក៏បញ្ជូនទ័ពយៀកមិញដែលស្លៀកពាក់ជាយោធាខ្មែរឲ្យមកបាញ់ប្រហារ «ប្រជាជនយួន៥០០០នាក់» បណ្ដែតទឹកត្រៀបត្រានៅអ្នកលឿង ហើយយកឧក្រិដ្ឋកម្មនេះទៅលាបឲ្យលន់-នល់ ។ ក្នុងមួយពព្រិចភ្នែក ពិភពលោកទាំងមូលបានស្អប់ខ្ពើមរអើមរដ្ឋាភិបាលលន់-នល់ ដែលត្រូវចោទថាជារដ្ឋាភិបាលឃាតករ ។ ពួកកុម្មុងដូសម្ងាត់យួនខាងជើង ក៏ចូលមកអារកប្រជាជនខ្មែរប្រុសស្រីនៅតាមក្រុងនិងខេត្ត ដោយតាំងខ្លួនថាជាទ័ពរបស់សីហនុ ។ ពួកយួនខាងត្បូងក៏ធ្វើអន្ដរាគមន៍ចូលមកប្លន់ រំលោភ កាប់សម្លាប់ប្រជាជនខ្មែរដើម្បីសងសឹក ។ តាមពិតគឺដើម្បីបណ្ដុះបណ្ដាលពូជខ្មែរក្រហម ។ នៅទីក្រុងប៉េកាំង ស្តេចសីហនុក៏ស្រែកអំពាវនាវ ឲ្យខ្មែររត់ចូលព្រៃម៉ាគី ក្នុងប្រការឲ្យទ័ពយួនខាងជើងបង្ហាត់បង្រៀន ឲ្យមកច្បាំងប្រហារពួកទីក្រុងភ្នំពេញ និងពួករដ្ឋាភិបាលលន់នល់-សិរិមតៈ ។ នៅទីបំផុត ក្នុងខែឧសភា១៩៧០ ចិនម៉ៅ-សេទុងក៏អនុញ្ញាតឲ្យបង្កើតរដ្ឋាភិបាលរំដោះ (ខ្មែរក្រហម) របស់ស្តេចសីហនុ ដែលស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់មេខ្មែរយៀកមិញជួន-មុំ ។

គឺដំណាក់ការចុងក្រោយនេះហើយ ដែលណែនាំប្រជាជាតិយើងឲ្យធ្លាក់ជាចំណីនៃ «មហាពស់នាគរាជប្រល័យពូជសាសន៍»ប៉ុល-ពតនៃខែមេសា១៩៧៥ ។

គឺពួកខ្មែរយើងទាំងអស់គ្នា ដែលសម្លាប់តែខ្មែរគ្នាឯងនេះហើយ ដែលជា«ក្បាលយួនខ្លួនខ្មែរ» ព្រោះយើងមើលឃើញតែដៃខ្មែរដែលសម្លាប់ខ្មែរ ប៉ុន្តែយើងមើលមិនឃើញខួរក្បាលនរណា ដែលសម្លាប់យើងនោះទេ ។ គឺជាខួរក្បាលយួន ដែលរស់នៅជាប់ក្បែរបង្កើយនិងសាច់ឈាមរបស់យើង (!!) ។៚

❑